មេរាគវ៉ែសណាយ
WEST NILE VIRUS

មេរោគវ៉ែសណាយ អាចការពារបាន! សូមអនុវត្តតាមវិធីបីយ៉ាងនេះ ដើម្បីកាត់បន្ថយកុំឲ្យមូសខាំ ។

1 សូមកំចាត់សំបុកមូសដែលមាននៅជិតផ្ទះលោក-អ្នក ។

- រៀងរាល់អាទិត្យ ចូរចាក់ទឹកពីធុងធំៗ, ពីធុងតូចៗនិងពីរទេះរុញធុងទឹកចេញឲ្យអស់
- ចូរចាក់ទឹកចេញពីប្រអប់ផ្សេងៗ ដូចជាប្រអប់តុក្កតាឬពីកំប៉ុងជាដើម
- ចូរចាក់ទឹកចេញពីអាងក្មេងលេងនៅពេលមិនប្រើការ
- ចូរសំអាតស្រះទឹកនៅក្នុងសួនច្បារ
- ចូរបោះកង់ឡានចាស់ៗចោលឲ្យអស់
- ចូរផ្ទាស់ទឹកក្នុងស្នូកសំរាប់សត្វចាបងូតនិងទឹកក្នុងស្នូកសំរាប់ពាហន៍: ឲ្យបានយ៉ាងហោចណាស់មួយអាទីត្យម្តង
- ចូរប្រមូលកំប៉ុងចាស់ៗនិងដបទុកឲ្យល្អ
- ចូរចាក់ទឹកចេញពីផើងផ្កា
- ចូរសំអាតទឹកចេញពីក្រណាត់ឬពីបា្ទស្ទីក ដែលមានទឹកដក់
- ចូរគ្របធុងទឹកភ្លៀងដោយប្រើក្រណាត់ការពារមូស
- ចូរជួយជនចាស់ជរា,បងប្អូន ឬអ្នកជិតខាងលោក-អ្នកនូវកិច្ចការទាំងនេះកុំខាន

2 ចូររៀបចំផ្ទះរបស់លោក-អ្នក

- ចូរសំអាតស្ទឹកឈើដែលស្ទះតាមទរទឹក ឬតាមប្រឡាយ
- ចូរជួសជុលបំពង់ទឹកលេចនៅក្រៅផ្ទះ
- ចូរជួសជុលសំណាញ់បង្អួចនិងសំណាញ់ទ្វាររហែក ឲ្យបិទជិតតឹងល្អ
- ចូរដាក់សំណាញ់យាំងទ្វារដែលបើកចេញចូលញឹកញាប់

3 ចូរប្រើប្រដាប់ការពារផ្ទាល់ខ្លួននៅពេលមូសខាំ

- ចូរស្បៀកខោនិងពាក់អាវដៃវែង
- គួរប្រើថ្នាំការពារសត្វល្អិតខាំ
- ថ្នាំការពារសត្វល្អិតប្រភេទ DEET មានប្រសិទ្ធភាពណាស់ ។
  – ចូរយកចិត្តទុកដាក់ និងអនុវត្តតាមរបៀបប្រើវា

ក្រសួងសាធារណ:សុខាភិបាល ក្រុងស៊ីអាថុលនិងតំបន់យីងខោនធី ខំធ្វើការ ដើម្បីកាត់បន្ថយនូវមេរោគវ៉ែសណាយ ដែលអាចប៉ះពាល់ដល់សង្គមរបស់យើង ។ ចូរមើលតាមគេហទំព័ររបស់យើង ឬក៏ទូរស័ព្ទមកដើម្បីបានពតិមានបន្ថែម:

http//www.metrokc.gov/health/westnile
206-205-3883(ម៉ាស៊ីន)

ក្រសួងសាធារណ:សុខាភិបាល ចង់ឲ្យពីលោក-អ្នក

បើសិនជាលោក-អ្នកយើញសត្វក្អែក,សត្វ blue jay ឬសត្វក្អែកប្រភេទធំស្ទាប់ ចូកត់ត្រាទីកន្លែង និងពេលវេលាដែលលោក-អ្នកបានយើញ ហើយបន្ទាប់មក ចូរទូរស័ព្ទ 206-205-4394 ដើម្បីរាយការណ៍ប្រាប់ ។ តាមកាល:ទេស:ខ្លះ យើងអាចទៅរើសយកសត្វនោះមកពិនិត្យមើល ។ ភាគច្រើន យើងនឹងប្រាប់ឲ្យបោះវាចោលក្នុងធុងសំរាម ។

ការបោះសត្វស្ទាប់ចោល

សត្វក្អែកនិងសត្វពាហន:ផ្សេងៗទៀត មិនចម្លងមេរោគវេសណាយ ដល់មនុស្សយើងទេ ។ លោក-អ្នកអាចធ្លាក់ខ្លួនឈឺដោយសារមូលខាំប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក៏ដោយ ចូរកុំប៉ះពាល់សត្វស្ទាប់នោះឲ្យសោះ,ត្រូវប្រើស្រោមដៃ ឬប្រើប៉ែលចូកវាដាក់ក្នុងថង់ប្ទាស្ទីកពីរជាន់ ។ ចូរបោះវាចោលទៅក្នុងធុងសំរាម ។

ចូរការពារកុំឲ្យមូសខាំ

Public Health
Seattle & King County

1202M
40236dh.fh8